# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០១៤.....សហវ.......

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានរបស់បេក្ខជនដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែង ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែងចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានជ្រាបថា បេក្ខជនទាំងពីរភេទត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានរបស់ខ្លួនក្នុងបញ្ជីរាយនាមបេក្ខជនដាក់ពាក្យចូលរួមប្រឡងប្រជែងចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ ដែលមានបិទផ្សាយនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ នៅនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ ឬនៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ឬនៅតាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ឬគេហទំព័រនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ www.pd.mef.gov.kh ឬគេហទំព័រវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ www.efi.mef.gov.kh។

ចំពោះបេក្ខជនដែលពិនិត្យឃើញមានកំហុសឆ្គងព័ត៌មានរបស់ខ្លួន ត្រូវស្នើសុំកែតម្រូវព័ត៌មានរបស់ខ្លួនឱ្យបានត្រឹមត្រូវនៅតាមទីកន្លែង កាលបរិច្ឆេទ និង ពេលវេលាដែលបានកំណត់ដូចខាងក្រោម ÷

- ទីកន្លែង : សាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ជាន់ទី ៩ បន្ទប់លេខ ៩០១
- កាលបរិច្ឆេទ : ចាប់ពីថ្ងៃទី ២៥ ខែ កញ្ញា ដល់ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៨
- ពេលវេលា : ពេលព្រឹកចាប់ពីម៉ោង ០៨:០០ នាទី ដល់ម៉ោង ១១:៣០ នាទីព្រឹក<br>ពេលរសៀលចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:០០ នាទីរសៀល
- បេក្ខជនត្រូវភ្ជាប់មកជាមួយនូវ : សលាកបត្រឯកត្តជនរបស់សាមីខ្លួន។

ក្នុងករណីបេក្ខជនមិនស្នើសុំកែតម្រូវព័ត៌មានរបស់ខ្លួនក្នុងរយៈពេលដូចបានជម្រាបជូនខាងលើ គណៈកម្មការប្រឡងមិនទទួលខុសត្រូវ និង ចាត់ទុកថាបេក្ខជនបានឯកភាពទាំងស្រុងលើបញ្ជីរាយនាមបេក្ខជនដែលបិទបានផ្សាយនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**រដ្ឋលេខាធិការ**
**ប្រធានគណៈកម្មការប្រឡង**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

**ចម្លងជូន÷**
- ឯកឧត្តមប្រធានគណៈកម្មការរៀបចំការប្រឡង
- វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ
- សាលាជាតិពន្ធដារ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន អពដ
- នាយកដ្ឋានហិរញ្ញវត្ថុ និង បុគ្គលិក អពដ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798